## ២. ការកែលម្អលក្ខខណ្ឌការងារល្អក្នុងកន្លែងធ្វើការងារ

ការលើកកំពស់សិទ្ធិការងារជាមូលដ្ឋានរបស់កម្មករនិយោជិត ក្រសួងមានគោលបំណងជាសំខាន់ គឺការពង្រឹងការដាក់ឱ្យអនុវត្តច្បាប់ ការអភិវឌ្ឍកម្មវិធីជាតិ ស្តីពីអនាម័យ និងសុវត្ថិភាពការងារ ( Occupation Health and Safety-OSH ) ការធ្វើយុទ្ធនាការលើកកំពស់ អនាម័យ និងសុវត្ថិភាពការងារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ ។

### ២.១. ផែនការពង្រឹងការដាក់ឱ្យអនុវត្តច្បាប់

- ស្រាវជ្រាវអំពីព័ត៌មាន និងឯកសារនានាសម្រាប់ការរៀបចំគោលការណ៍ស្តីពីប្រាក់ឈ្នួល
- លើកកំពស់សមត្ថភាពធនធានមនុស្ស ស្តីពីការយល់ដឹងអំពីលក្ខខណ្ឌល្អនៅក្នុងទីកន្លែងធ្វើការ
- រៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ដែលស្តីពីបញ្ហានានានៃលក្ខខណ្ឌការងារ
- ផ្សព្វផ្សាយបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដល់និយោជក និងកម្មករនិយោជិត
- ផ្តល់ព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ចអំពីការរំលោភផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងវិស័យការងារ
- តាមដានការវិវត្តនៃនីតិការងារ និងស្នើសុំយោបល់ថ្នាក់លើបញ្ចូលបទប្បញ្ញត្តិថ្មីៗ ទៅក្នុងច្បាប់ឬបទបញ្ជាដែលមានរួចហើយ ក្នុងករណីដែលយល់ឃើញថាចាំបាច់ និងស្នើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ
- រៀបចំការងារអធិការកិច្ច

- តាមដានត្រួតពិនិត្យមើលសកម្មភាពអធិការកិច្ចការងារ ។

## ២.២. ជម្រុញការអនុវត្តច្បាប់ និងការអភិវឌ្ឍកម្មវិធីជាតិស្តីពីប្រព័ន្ធអនាម័យ និងសុវត្ថិភាពការងារ

- រៀបចំធ្វើប្រកាស និងបទប្បញ្ញត្តិផ្សេងៗស្តីពីអនាម័យ និងសុវត្ថិភាពការងារ (Occupation Health and Safety-OSH )
- ធ្វើគោលនយោបាយជាតិស្តីពី (Occupation Health and Safety-OSH) នៅកន្លែងធ្វើការងារ
- ធ្វើអធិការកិច្ចដើម្បីត្រួតពិនិត្យ និងតាមដានលក្ខខណ្ឌ OSH
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការអនុវត្តវិធានការ OSH ដល់សហគ្រាស គ្រឹះស្ថាន ។

## ២.៣. ពង្រឹងប្រព័ន្ធគ្រប់គ្រង OSH និងអភិវឌ្ឍធនធានមនុស្ស

ធ្វើការបណ្តុះបណ្តាល OSH ដល់មន្ត្រីពាក់ព័ន្ធ និងគ្រូពេទ្យសហគ្រាស ។

## ២.៤. ការពារ និងធ្វើការអង្កេតគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ និងជម្រុញការងារទប់ស្កាត់ *HIV/AIDS* នៅកន្លែងធ្វើការ

- ធ្វើការអង្កេតមុន និងក្រោយគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ ឬតាមការដ្ឋាន
- ជម្រុញការអនុវត្តប្រកាសក្រសួង ស្តីពីការបង្កើតក្រុម-

ការងារ ឬគណៈកម្មការ HIV/AIDS នៅកន្លែងធ្វើការ ។

## ២.៥. លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

- ដកហូតកុមារពីការងារប្រកបដោយគ្រោះថ្នាក់
- ផ្តល់ការអប់រំ និងបណ្តុះបណ្តាលដល់កុមារធ្វើការងារឱ្យ បានច្រើន ដើម្បីកុមារទទួលបានការបណ្តុះបណ្តាលកាន់ តែច្រើន ហើយមិនចូលរួមក្នុងការងារនៃទម្រង់ធ្ងន់ធ្ងរ និងប្រកបដោយគ្រោះថ្នាក់
- សមាហរណកម្មកុមារធ្វើការងារទៅក្នុងសហគមន៍ ដើម្បី ធានាឱ្យបានថាពួកគេបានចូលរៀន បង្កើនកំរិតវប្បធម៌ និងទទួលបានការអប់រំផ្សេងៗទៀត ។

## ២.៦. ផែនការជាតិ៥ឆ្នាំ ស្តីពីការលុបបំបាត់ទម្រង់ ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០០៨-២០១២

- ផ្សព្វផ្សាយ និងជម្រុញការអនុវត្តផែនការជាតិ
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីនៅតាមខេត្ត-ក្រុង ដើម្បី បញ្ចូលបញ្ហាពលកម្មកុមារទៅ ក្នុងផែនការខេត្ត-ក្រុង
- អភិវឌ្ឍបទអន្តរាគមន៍ទាំង ៨ របស់ផែនការជាតិ ។